# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបិទឆ្នាំសិក្សានៅទេវវិទ្យាល័យ
# ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩
# យកចិត្តទុកដាក់លះបង់ចោលដើម្បីបម្រើ

**អត្ថបទទី១៖ កំណើតពិភពលោក ១៦,១-១២.១៥-១៦**

ទេវទូតរបស់ព្រះអម្ចាស់ពោលទៅនាងថា៖ «ចូរវិលត្រឡប់ទៅផ្ទះម្ចាស់របស់នាងវិញ ហើយស្តាប់បង្គាប់គាត់ទៅ»។ កណ ១៦,៩

**ដំណឹងល្អ៖ ម៉ាថាយ ៧,២១-២៩**

អ្នកណាស្តាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម។ មថ ៧,២៤

បងប្អូនជាទីស្រឡាញ់!

ខែមិថុនា ជាខែល្អសម្រាប់យើងដែលជាគ្រីស្តបរិស័ទ ជាខែដែលយើងគោរពព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ ជាខែមួយដែលយើងទទួលពន្លឺពីព្រះជាម្ចាស់ នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ជាពេលវេលាដែលយើងគោរពសន្តប៉ូលនិងសន្តសិលា ដែលណែនាំឲ្យយើងពោរពេញដោយកម្លាំង ដើម្បីកសាងព្រះសហគមន៍របស់យើង។ ថ្ងៃនេះជាពេលវេលាមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់លោកឪពុកប៉ប់ ដែលបានទទួលខុសត្រូវលើទេវវិទ្យាល័យ។ ក្នុងអត្ថបទគម្ពីរដំណឹងល្អ យើងនឹកឃើញរបៀបដែលលោកឪពុកប៉ប់ បានបម្រើទេវវិទ្យាល័យរយៈពេល៩ឆ្នាំកន្លងមក។ នៅពេលយើងជាកូនសិស្សលោកអភិបាល យើងរៀនសូត្រនៅទីនេះពីមួយឆ្នាំទៅមួយឆ្នាំ យើងយកចិត្តទុកដាក់ទៅបម្រើព្រះសហគមន៍មួយចំនួនរៀងរាល់ចុងសប្តាហ៍ ដើម្បីឲ្យយើងចាប់ផ្តើមភ្ជាប់នឹងជីវិតពិតៗនៃព្រះសហគមន៍។ យើងយកចិត្តទុកដាក់ដើម្បីអធិដ្ឋានជាប្រចាំ យើងយកចិត្តទុកដាក់ដើម្បីរៀបចំចិត្តគំនិតរបស់យើងជាមនុស្សដ៏ពេញលក្ខណៈ ប៉ុន្តែជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ពោរពេញដោយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

នាយកទេវវិទ្យាល័យសំខាន់ណាស់ ជាពន្លឺមួយដើម្បីដឹកនាំ ជាពន្លឺមួយដើម្បីធ្វើដំណើរ ជាពន្លឺមួយដើម្បីឲ្យយើងជាក្រុមមួយដែលខិតខំរស់នៅជាមួយគ្នា ឲ្យយើងចេះសម្រុះសម្រួលគ្រប់បញ្ហាជាមួយគ្នាពីមួយថ្ងៃទៅមួយថ្ងៃជាប្រចាំ។ នាយកទេវវិទ្យាល័យ មិនមែនដើម្បីវិនិច្ឆ័យកាត់ក្តី នាយកជាគំរូមួយដើម្បីណែនាំប្អូនៗដែលជានិស្សិតទេវវិទ្យាល័យ ឲ្យយកចិត្តទុកដាក់រៀបចំខ្លួនដើម្បីចូលនៅក្នុងព្រះហឫទ័យព្រះជាម្ចាស់។ គម្ពីរដែលយើងបានស្តាប់ថ្ងៃនេះ យើង

អាចនឹកឃើញអ្វីៗទាំងអស់ដែលលោកឪពុកប៉ប់ បានយកចិត្តទុកដាក់សាងសង់នៅក្នុងទេវវិទ្យាល័យកន្លងមក។ យើងបានស្តាប់ព្រះយេស៊ូមានព្រះបន្ទូលថា "**មិនមែនអ្នកដែលចេះតែនិយាយថាព្រះអង្គម្ចាស់ៗប៉ុណ្ណោះទេ គឺអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំដែលគង់នៅស្ថានបរមសុខនោះវិញ**" ខ្ញុំជឿថារបៀបដែលលោកឪពុកប៉ប់ បានណែនាំទេវិទ្យាល័យ៩ឆ្នាំកន្លងមក គឺបានណែនាំឲ្យម្នាក់ៗអាចនឹកឃើញដល់ព្រះហឫទ័យព្រះជាម្ចាស់។ នៅពេលយើងចូលនៅក្នុងទេវវិទ្យាល័យ យើងគិតថានេះជាគោលបំណងរបស់យើង យើងចង់ធ្វើជាបូជាចារ្យ ដើម្បីដើរតាមការត្រាស់ហៅដែលព្រះជាម្ចាស់មានសម្រាប់ខ្ញុំ។ មុនដំបូងជាគោលបំណងរបស់យើងពិតមែន នៅពេលយើងចូលនៅក្នុងទេវវិទ្យាល័យយើងចាប់ផ្តើមយល់ថា **តើធ្វើយ៉ាងណាដើម្បីឲ្យគោលបំណងរបស់យើង អាចចូលក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់?** ដោយសារយើងឆ្លើយតបព្រះហឫទ័យព្រះជាម្ចាស់ ដើម្បីបម្រើព្រះជាម្ចាស់។ ខ្ញុំជឿថាលោកឪពុកប៉ប់ បានជួយមើលណែនាំរបៀបដែលគាត់បានជួបជាប្រចាំ ដើម្បីឲ្យយើងមានអំណានផ្លូវការនៅក្នុងជីវិតជាប្រចាំថ្ងៃ **តើព្រះជាម្ចាស់មានស្នាព្រះហស្តដូចម្តេច ដើម្បីណែនាំជីវិតរបស់យើងទៅជាអ្នកបម្រើអស់មួយជីវិត?**

"**អ្នកណាដែលស្តាប់ពាក្យរបស់ខ្ញុំ ហើយប្រព្រឹត្តតាម**" លោកឪពុកប៉ប់ ទោះបីលោកចាស់ហើយលោកព្យាយាមរៀនភាសាខ្មែរ លះបង់ចោលបេសកកម្មដែលគាត់បានទទួលយូរឆ្នាំនៅប្រទេសហ្វីលីភីនដើម្បីមកទីនេះ ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកឪពុកប៉ប់ បានយកចិត្តទុកដាក់លះបង់ចោលដើម្បីបម្រើ សម្រាប់យើងដែលជាអ្នកត្រៀមខ្លួនធ្វើជាបូជាចារ្យ ឲ្យយើងចេះលះបង់ចោល ស្តាប់បង្គាប់ យកចិត្តទុកដាក់ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដែលយើងអនុវត្តយ៉ាងសកម្មនៅក្នុងជីវិតរបស់យើងជាប្រចាំ។ យើងមិនមែនប្រកាសព្រះបន្ទូល ដោយស្រែកឲ្យគេឮប៉ុន្តែប្រកាសដើម្បីឲ្យគេឃើញតាមជីវិតផ្ទាល់ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បំភ្លឺជីវិតរបស់យើងដូចម្តេច? អាចណែនាំឲ្យគ្រីស្តបរិស័ទអាចចូលនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីអនុវត្តតាមផ្ទាល់។

"**មនុស្សឈ្លៀសវៃម្នាក់ ដែលបានសាងសង់ផ្ទះនៅលើផ្ទាំងថ្ម**" យើងមានលោកឪពុកប៉ប់ដែលជាលោកតាឈ្លៀសវៃម្នាក់ ដែលបានដឹកនាំខាងផ្លូវវិញ្ញាណ និងជួយយោបល់ដើម្បីឲ្យយើងចេះមើលឃើញវែងឆ្ងាយ។ យើងមានសំណាងណាស់ ដែលបានឃើញលោកឪពុកម្នាក់ឈ្លៀសវៃ និងបានសាងសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម ដែលជាព្រះយេស៊ូផ្ទាល់ ជាមូលហេតុរឹងមាំដើម្បីបម្រើតាមអ្វីដែលព្រះយេស៊ូបានប្រទានឲ្យ។ អត្ថបទនេះសម្រាប់យើងនៅប្រទេសកម្ពុជា យើងមានឧទាហរណ៍ជាក់ស្តែងនៅកំពង់សោម នៅពេលយើងសាងសង់មិនរឹងមាំ ធ្វើឲ្យអាគារនោះរលំអស់។ នៅពេលយើងឃើញផ្ទាល់ភ្នែក ហើយយើងស្តាប់ព្រះបន្ទូលនេះឲ្យយើងយល់ថានេះ

ជាសេចក្តីពិត ជីវិតរបស់យើងអាចទៅមុខបានលុះត្រាតែ យើងសាងសង់ផ្ទះនៃជីវិតទៅលើព្រះយេស៊ូគ្រីស្ត។ សម្រាប់និស្សិតទេវវិទ្យាល័យ ដើម្បីតស៊ូនៅក្នុងជីវិត ដើម្បីសម្រុះសម្រួលគ្រប់បញ្ហា យើងត្រូវការមានធានារ៉ាប់រងយ៉ាងរឹងមាំដើម្បីទៅមុខ។

នៅពេលគេស្តាប់ព្រះយេស៊ូគេឆ្ងល់ ដោយសារព្រះអង្គមានព្រះបន្ទូលប្រកបដោយអំណាច ខុសប្លែកពីពួកបណ្ឌិតខាងវិន័យ។ នៅពេលព្រះយេស៊ូមានព្រះបន្ទូលតែមួយម៉ាត់ ធ្វើឲ្យគេមានអារម្មណ៍ថានេះជាព្រះបន្ទូលដែលចេញពីព្រះជាម្ចាស់។ លោកឪពុកប៉ប់ នៅពេលគាត់ធ្វើរបាយការណ៍ច្បាស់ណាស់ ពេលគាត់បង្រៀននៅសាលាសន្តយ៉ូស្ទីនច្បាស់ណាស់ ខ្ញុំជឿថាលោកឪពុកចូលនៅក្នុងនេះ អ្នកដែលនិយាយប្រកបដោយអំណាច ដោយសារគំនិតច្បាស់ ជំនឿច្បាស់ ដូច្នេះនៅពេលពន្យល់អាចបំភ្លឺយ៉ាងច្បាស់។ ដូច្នេះខ្ញុំសង្ឃឹមនិស្សិតទេវវិទ្យាល័យ នៅពេលអនាគតយើងជាបូជាចារ្យកុំឲ្យយើងទេសនាដូចពួកបណ្ឌិតខាងវិន័យ ដែលចេះតែនិយាយទៅណាទៅណី ឲ្យយើងនិយាយដើម្បីណែនាំឲ្យបងប្អូនអាចរកឃើញសេចក្តីពិតនៅក្នុងជីវិត សេចក្តីពិតគឺព្រះយេស៊ូផ្ទាល់ ឲ្យគេរកឃើញផ្លូវទៅកាន់ជីវិត ផ្លូវគឺព្រះយេស៊ូផ្ទាល់ ឲ្យគេរកឃើញជីវិតដែលជាព្រះយេស៊ូផ្ទាល់។ យើងអាចធ្វើបាន លុះត្រាតែពីមួយថ្ងៃទៅមួយថ្ងៃពីមួយឆ្នាំទៅមួយឆ្នាំ យើងបន្តសាងសង់ផ្ទះរបស់យើងទៅលើព្រះយេស៊ូនៅក្នុងការអធិដ្ឋាន នៅក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជានិច្ច និងនៅក្នុងការយកចិត្តទុកដាក់ស្រឡាញ់បងប្អូន ដែលយើងបានទទួលទាំងនៅក្នុងនិងក្រៅព្រះសហគមន៍ដែរ។

យូរៗម្តងឲ្យយើងអានព្រះបន្ទូលដែលយើងបានស្តាប់ថ្ងៃនេះ ដោយនឹកឃើញដល់លោកឪពុកប៉ប់ នឹកឃើញជីវិតរបស់យើងនៅថ្ងៃអនាគតដើម្បីបន្តរួមជាមួយគ្នា ដើម្បីកសាងព្រះសហគមន៍យើង។ អរគុណបងប្អូនដែលបានគាំទ្រទេវវិទ្យាល័យ ជាពិសេសឪពុកម្តាយដែលបានណែនាំអប់រំកូន និងបានឯកភាពឲ្យកូនធ្វើដំណើរជាមួយព្រះសហគមន៍ ដើម្បីបម្រើព្រះសហគមន៍អស់មួយជីវិត។ យើងដឹងថាព្រះជាម្ចាស់ប្រទានពរដល់បងប្អូន ឪពុកម្តាយ លោកតាលោកយាយ ដែលបានអធិដ្ឋានឲ្យកូនដើម្បីបម្រើព្រះសហគមន៍ ឲ្យព្រះសហគមន៍ទៅជាសញ្ញាសម្គាល់នៃជីវិត នៃសេចក្តីពិតដែលមកពីព្រះយេស៊ូផ្ទាល់។ យើងអរព្រះគុណព្រះជាម្ចាស់ យើងអធិដ្ឋានដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍មួយដែលបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជានិច្ច។ អាម៉ែន៕